01104200

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**D236/1/1/5**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ២០)

| | | |
|---|---|---|
| | ចៅក្រម ប្រាក់ គឹមសាន | ប្រធាន |
| ចំពោះមុខ: | ចៅក្រម Oliver BEAUVALLET | |
| | ចៅក្រម នីយ ថុល | |
| | ចៅក្រម Steven BWANA | |
| | ចៅក្រម ហួត វុទ្ធី | |
| កាលបរិច្ឆេទ: | ថ្ងៃទី៩ ខែមិថុនា ឆ្នាំ ២០១៥ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 06 / 2015
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## សម្ងាត់

## សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលកំណត់ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី អ៊ឹម ចែម**

ប៊ិត ស៊ាងលីម
John R.W.D. Jones QC

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អ្នកដាក់ពាក្យស្នើជា ដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលកំណត់ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម" ដែលបានដាក់នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥ ("សំណើ")[1]។

1. នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់ "បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើញត្តិរបស់អ្នកស្រី ស្នើសុំឱ្យពិចារណាឡើងវិញ និងលុបចោលដីកាកោះហៅ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤" ("បណ្តឹងឧទ្ធរណ៍ស្តីអំពីដីកាកោះ")[2]។ នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់ "បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចដាក់អ្នកស្រីឱ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ*" ("បណ្តឹងឧទ្ធរណ៍ស្តីអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ")[3]។ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ការិយាល័យសហព្រះរាជអាជ្ញាទទួលបានការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ទាំងពីរនេះ (ហៅបណ្តឹងទាំងពីរនេះថា "បណ្តឹងឧទ្ធរណ៍") នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ តាមរយៈសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") ស្នើសុំពន្យារពេលចំនួន ១០ ថ្ងៃ ហើយកាលបរិច្ឆេទកំណត់សម្រាប់ចម្លើយតបរបស់គាត់ (ហៅ ចម្លើយតបទាំងពីរថា "ចម្លើយតប") ទៅនឹងបណ្តឹងឧទ្ធរណ៍ ត្រូវកំណត់យកថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ និងស្នើសុំដាក់ចម្លើយតបជាភាសាអង់គ្លេសជាមុនសិន ដោយដាក់សំណៅបកប្រែជា ភាសាខ្មែរតាមក្រោយ។

2. នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលធ្វើការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ (មេធាវីការពារក្តីឆ្លើយតបនឹងសំណើ)[4]។ មេធាវីការពារក្តីពុំជំទាស់នឹងសំណើរបស់សហព្រះរាជអាជ្ញាទេ[5] ហើយដោយហេតុនេះ មេធាវីការពារក្តីស្នើសុំពេលប្រាំថ្ងៃថែមទៀត ដើម្បីដាក់ការឆ្លើយតបរបស់

[1] ឯកសារ D239/1/3។

[2] ឯកសារ D236/1/1/2។

[3] ឯកសារ D239/1/2។

[4] ឯកសារ D239/1/4។

[5] ចម្លើយតបមេធាវីការពារក្តី កថាខណ្ឌ១។

E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ខ្លួន (រួមគ្នាហៅថា "ចម្លើយតប") ទៅនឹងការឆ្លើយតប ហើយសុំដាក់ចម្លើយតបជាភាសាអង់គ្លេសជាមុនសិនការបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ[6]។

3. អនុលោមតាមមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្ត")[7] "សារណាតបណាមួយទៅនឹងពាក្យសុំ ឬសារណា ត្រូវដាក់រួមគ្នាជាមួយបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលប្រើប្រាស់ជាឯកសារយោង ក្នុងរយៈពេល ១០ថ្ងៃ នៃប្រតិទិន គិតពីថ្ងៃជូនដំណឹងនៃឯកសារដែលត្រូវឆ្លើយតប"។ អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្ត អង្គជំនុំជម្រះអាចពន្យារពេលវេលាកំណត់តាមពាក្យសុំរបស់ភាគីណាមួយ ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន។ សហព្រះរាជអាជ្ញាអះអាងថា បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធជាមួយបញ្ហាច្បាប់ដ៏ស្មុគស្មាញទាក់ទិននឹងយុត្តាធិការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងទំនាក់ទំនងរវាងច្បាប់ជាតិ និងអន្តរជាតិ[8]។ សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា ការខកខានរបស់នគរបាលយុត្តិធម៌ក្នុងការអនុវត្តដីកានាំខ្លួន ដែលពួកគេជាក់ស្តែងបានទទួលយកថាត្រឹមត្រូវនោះ[9] បង្កើតឲ្យមានស្ថានភាពអង្គហេតុមួយ ដែលអ្នកតាក់តែងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានប្រមើលពីមុនមក[10] ហើយថា បណ្តឹងឧទ្ធរណ៍មាន "អំណះអំណាងយ៉ាងទូលំទូលាយ ដែលបានពឹងផ្អែកលើប្រភពខុសៗគ្នាជាច្រើនចេញពីយុត្តាធិការមួយចំនួនធំ"[11]។

4. អង្គបុរេជំនុំជម្រះយល់ឃើញថា សហព្រះរាជអាជ្ញា នៅក្នុងសំណើរបស់ខ្លួន បានផ្តល់នូវការបញ្ជាក់គ្រប់គ្រាន់ស្តីអំពីភាពស្មុគស្មាញនៃបញ្ហាអង្គច្បាប់ និងអង្គហេតុ ដែលបានលើកឡើងនៅក្នុង

---

[6] ចម្លើយតបមេធាវីការពារក្តី កថាខណ្ឌ១ និង៤។

[7] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិ. ០៨ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២។

[8] សំណើ កថាខណ្ឌ ៤។

[9] សំណើ កថាខណ្ឌ ៤។ សូមមើល ដីកាសម្រេចដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D239 កថាខណ្ឌ ២១-៣០។

[10] សំណើ កថាខណ្ឌ ៤។ *សូមមើល* មាត្រា ២៥(គ) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទិននឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ និងវិធាន ១៥ នៃវិធានផ្ទៃក្នុង។

[11] សំណើ កថាខណ្ឌ ៥។

បណ្តឹងឧទ្ធរណ៍ ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញក្នុងន័យនេះ ព្រមជាមួយនឹងអង្គហេតុថា មេធាវីការពារក្តី មិនបានជំទាស់នឹងសំណើរបស់សហព្រះរាជអាជ្ញាដែរ[12]។

5. ជាងនេះទៀត អនុលោមតាមមាត្រា ៧.១ នៃសេចក្តីណែនាំអនុវត្ត "គ្រប់ឯកសារទាំងអស់ត្រូវដាក់ជាភាសាខ្មែរ រួមជាមួយភាសាអង់គ្លេស ឬបារាំង"។ ទោះបីជាយ៉ាងណាក៏ដោយ មាត្រា ៧.២ ចែងថា "នៅក្នុងកាលៈទេសៈពិសេស សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនៃ អ.វ.ត.ក អាចអនុញ្ញាតឱ្យ ភាគីណាមួយដាក់ឯកសារជាភាសាបារាំង ឬភាសាអង់គ្លេសជាបឋមបាន ប៉ុន្តែបន្ទាប់មក ភាគីត្រូវដាក់ឯកសារជាភាសាខ្មែរដែលបានបកប្រែរួចឱ្យបានឆាប់រហ័សបំផុត"។ សហព្រះរាជអាជ្ញាអះអាងថា ដោយសារ*បណ្តឹងឧទ្ធរណ៍*មានចំនួនសរុប ៣៨ ទំព័រ ចម្លើយតបអាចនឹងមានចំនួនទំព័រប្រហែលគ្នានេះដែរ[13]។ សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា ទោះបីជាការិយាល័យសហព្រះរាជអាជ្ញា ជាទូទៅ ធ្វើការបកប្រែសារណារបស់ខ្លួនជាភាសាខ្មែរ ដោយខ្លួនឯងក៏ដោយ ក៏ការិយាល័យសហព្រះរាជអាជ្ញានឹងមិនមានលទ្ធភាពបកប្រែជាភាសាខ្មែរ តាមកាលបរិច្ឆេទដែលបានកំណត់នោះឡើយ ដោយសារតែចម្លើយតបទាំងពីរដែលអាចមាន ច្រើនទំព័រត្រូវដាក់ក្នុងពេលតែមួយនោះ[14]។

6. អង្គបុរេជំនុំជម្រះកត់សម្គាល់អំពីចម្លើយតបដែលអាចមានច្រើនទំព័រ ភាពស្មុគស្មាញនៃបញ្ហានានានៅក្នុងចម្លើយតបនោះ និងបន្ទុកការងារបកប្រែឯកសារដែលនឹងមានចំនួនច្រើននេះ ដូចដែលបានលើកឡើងផងដែរនៅក្នុងបណ្តឹងឧទ្ធរណ៍[15]។ អង្គបុរេជំនុំជម្រះយល់ឃើញថា មានកាលៈទេសៈពិសេស ដែលអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបជាភាសាអង់គ្លេសជាមុនសិន ដោយត្រូវដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ ក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន។

---

[12] ចម្លើយតបមេធាវីការពារក្តី កថាខណ្ឌ១ និង៤។

[13] សំណើ កថាខណ្ឌ ៩។

[14] សំណើ កថាខណ្ឌ ៩។

[15] បណ្តឹងឧទ្ធរណ៍ស្តីអំពីដីកាកោះ កថាខណ្ឌ ៦។ បណ្តឹងឧទ្ធរណ៍ស្តីអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ កថាខណ្ឌ ៥។ *សូមមើល* សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំដាក់បណ្តឹងឧទ្ធរណ៍ស្តីពីការដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ជាភាសាអង់គ្លេសមុន ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D239/1/1។

7. ដោយសារភាពស្រដៀងគ្នានៃបញ្ហាដែលបានលើកឡើង និងដើម្បីធានាភាពស្មើគ្នាចំពោះភាគី អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាមានភាពសមស្របនឹងទទួលសំណើរបស់មេធាវីការពារក្តី សុំបន្ថែមពេលប្រាំថ្ងៃទៀត ដើម្បីដាក់ការឆ្លើយតបណាមួយ និងដាក់ជាភាសាអង់គ្លេសជាមុនសិន ដោយត្រូវដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេច ៖**

**យល់ស្រប** តាមសំណើ។

**អនុញ្ញាត** ពន្យារពេល១០ ថ្ងៃ សម្រាប់សហព្រះរាជអាជ្ញាដាក់ចម្លើយតប ទៅនឹងបណ្តឹងឧទ្ធរណ៍ ត្រឹមថ្ងៃ ទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥។

**អនុញ្ញាត** ឱ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបជាភាសាអង់គ្លេសជាមុនសិន ដោយត្រូវដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ។

**អនុញ្ញាត** ឱ្យពេលប្រាំថ្ងៃបន្ថែម សម្រាប់មេធាវីការពារក្តីដាក់ការឆ្លើយតបណាមួយ។

**អនុញ្ញាត** ឱ្យមេធាវីការពារក្តីដាក់ចម្លើយតបជាភាសាអង់គ្លេសជាមុនសិន ដោយត្រូវដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៥

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

**ប្រាក់ គឹមសាន**